# បែបហាត់សរសេរ

# អក្សរផ្ចង់

គំរូនឹងសេចក្ដីណែនាំនូវការសរសេរអក្សរផ្ចង់

ជ្រៀង - ឈរ - ខម - មូល - ស្រមោល - ក្បាច់

**METHODE PRATIQUE D'ECRITURE KHMERE**

បណ្ណាគារ ប៊ុក-ឆាខ

លេខ ១៧៦ រុក្ខវិថីខេមរភូមិន្ទ ក្រុងភ្នំពេញ

រក្សាសិទ្ធិ

CAPSEA

អំណោយនៃសមាគមជំនួយវប្បធម៌អាស៊ីអាគ្នេយ៍

Donated by "Cultural Aid Project for South-East Asia"

ហាមលក់

បែបហាត់សរសេរ

# អក្សរផ្ចង់

គំរូនិងសេចក្ដីណែនាំនូវការសរសេរអក្សរផ្ចង់

ជ្រៀង . ឈរ . ខម . មូល . ស្រមោល . ក្បាច់

**Méthode pratique d'écriture khmère**

រៀបរៀងតាមកម្មវិធីគរុកោសល្យ

សម្រាប់គ្រប់ថ្នាក់

ផ្សាយពី

បណ្ណាគារប៊ុន.ឆាយ

លេខ ១៧៦ រុក្ខវិថីខេមរភូមិន្ទ ក្រុងភ្នំពេញ

ព. ស. ២៥០០ គ. ស. ១៩៥៧

(ឯកសិទ្ធិ)

# សេចក្តីថ្លែងអំណរគុណ

សៀវភៅនេះបានរក្សាទុកដោយ លោក នឹង លោកស្រី វ៉ាតាណាបេត្សឹ, ជីអេកូ ហើយបានអំណោយមក សមាគមជំនួយវប្បធម៌ អាស៊ី - អាគ្នេយ៍ ដើម្បីឱ្យសមាគមបោះពុម្ព ។

សមាគមសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអំណោយដ៏មានសារសំខាន់នេះ ហើយសូមឧទ្ទិសឱ្យសៀវភៅនេះ បានជាប្រយោជន៍ធំសំរាប់ទ្រទ្រង់អក្សរជាតិ វប្បធម៌ជាតិ ។

សមាគមជំនួយវប្បធម៌ អាស៊ី - អាគ្នេយ៍

*ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៨*

ប៉ែន សេដ្ឋារិន

# ពាក្យប្រារព្ធ

មានមនុស្សជាច្រើនដែលចេះនិយាយ, ចេះអធិប្បាយសេចក្ដីគ្រោះក្បាយ គួរជាទីសណ្ដាប់នៃអ្នកផង ឬចេះអានសំបុត្រស្នាម ឬរឿងរ៉ាវក្នុងសៀវភៅផ្សេងៗ ហូរហែខ្លះ, ប៉ុន្តែពុំសូវបិនស្របខាងការសរសេរអក្សរឲ្យបានល្អត្រឹមត្រូវតាមក្បួនខ្នាត ដែលយកជាការពុំកើត គឺថាសរសេរអក្សរក្រវេមក្រវាម រាត់ជើងរាត់សក់វែងៗហួសពីតួខ្លួន ទៅលើតួឯទៀតៗឲ្យតែរួចពីដៃទៅ ជាហេតុនាំឲ្យទទើសទទែងរសេមរសាមពិបាកអានពន់ពេក ដែលពាក្យបុរាណហៅថា «សរសេរអក្សរដូចជើងក្ដាម» ។ បើត្រូវការសរសេរអក្សរម្ដងៗ ឡើង តោងតែទៅពឹងឬជួលពីអ្នកដែលចេះសរសេរអក្សរល្អត្រឹមត្រូវឲ្យគេសរសេរឲ្យ, ម្ល៉ោះហើយក៏កើតសេចក្ដីធុញទ្រាន់បង្អៀតបង្អល់ក្នុងចិត្តពេកណាស់ ។

នៅគ្រប់សាលារៀន, គេបង្ហាត់សិស្សឲ្យរៀនសរសេរអក្សរល្អ គឺអក្សរផ្ចង់ តាមបែបអក្សរជ្រៀង, អក្សរឈរ, អក្សរខម, អក្សរមូល ដែលមានបំណងដើម្បីបង្ហាត់សិស្សឲ្យមានទម្លាប់ដៃ, ទម្លាប់ចិត្ត ឲ្យថ្នឹកខាងការសរសេរ ឲ្យបានរៀបរយល្អត្រឹមត្រូវតាមក្បួនខ្នាត, កុំឲ្យសរសេរគ្រវីសគ្រវាស ឲ្យតែរួចពីដៃនោះ ។ បើសិស្សមានទម្លាប់ស្ទាត់ដៃនឹងចិត្តជួលទៅតែខាងល្អ, ខាងស្អាត មានបែបផែនទៅហើយ, ទោះសរសេរតួអក្សរមិនបានល្អក៏ដោយចុះ, ប៉ុន្តែគង់តែសរសេរបានស្អាតបាតមានរបៀបរៀបរយ ត្រឹមត្រូវតាមក្បួនខ្នាត, មិនប្រងេងប្រងាងទទើសទទែងនាំឲ្យពិបាកអាននោះឡើយ ។

តម្រានេះ មានប្រយោជន៍យ៉ាងសំខាន់ ព្រោះជាជំនួយដល់សាលារៀនទូទៅ, ក្នុងតម្រានេះមានពន្យល់ណែនាំសិស្សឲ្យចេះសរសេរអក្សរផ្ចង់ ត្រឹមត្រូវតាមខ្នាតគ្រប់យ៉ាង ឲ្យបានសមរម្យតាមបែបផែន ដែលគេបានកម្រិតយ៉ាងម៉ត់ចត់ទុកមក ដើម្បីជៀសវាងទម្លាប់អាក្រក់ ដែលសរសេរឲ្យរួចតែពីដៃទៅ ដូចមានពោលខាងលើ ។

អក្សរផ្ចង់ចែកជាក្រុមផ្សេងៗពីគ្នា, ក្នុងអក្សរមួយក្រុមៗ មានៈ តួ, សក់, ស្រះ, ជើង, ជើងជើង, ក្រវាត់ស្រដៀងៗគ្នា ។ ឯតួអក្សរចែកជាបីបែបគឺៈ តួធំ, តួមធ្យម និងតួតូច ។ ឯតួអក្សរមានច្រើនយ៉ាងណាស់ ដ្បិតអ្នករចនាតួអក្សរជាន់ក្រោយចែកច្រាជ្ញាតាមសម័យនិយមនៃប្រទេសឯករាជ្យ ដែលអាចនាំឲ្យអក្សរសាស្ត្រជាតិយើងមានវឌ្ឍនភាពតែសមរម្យឡើងៗ ជាលំដាប់ ។

នៅក្នុងតម្រានេះ, យើងបាននាំយកព្យញ្ជនៈនិងស្រៈ ដែលជាអក្សរមេរៀន មកធ្វើជាគំរូគឺៈ តួជ្រៀង, ឈរ, មូល, ខម (អក្សរមូលច្រើនមានប្រើតាំងពីក្នុងក្បួនខ្នាតឬសាស្ត្រាស្លឹករឹតជាន់បុរាណ) សម័យឥឡូវនេះ គេនិយមប្រើអក្សរខមជាងអក្សរមូល ។

នៅភាគខាងចុងនៃតម្រានេះ, យើងបានភ្ជាប់ជាមួយផង នូវអក្សរផ្ចង់ព្យញ្ជនៈបាលី ដែលប្រទេសយើងនៅមានប្រើខ្លះនៅឡើយ, ប៉ុន្តែអក្សរបាលីគេមានក្បួនខ្នាតគេច្រើនបែបច្រើនយ៉ាងណាស់ទៅហើយ, យើងគ្រាន់តែរើសយកតួព្យញ្ជនៈខ្លះមកធ្វើជាគំរូ ឬជាមេរៀននៃអក្សរផ្ចង់ឲ្យសិស្សរៀនសរសេរបានល្អប៉ុណ្ណោះឯង ។

ទីបំផុត, ខ្ញុំមានសង្ឃឹមថាតម្រានេះ គង់មានប្រយោជន៍ដល់លោកគ្រូ-អ្នកគ្រូ យកទៅបង្ហាត់បង្រៀនសិស្សឲ្យចេះសរសេរអក្សរល្អត្រឹមត្រូវតាមក្បួនខ្នាតនេះជាពុំខាន ។

សួស្តីអក្សរសាស្ត្រជាតិ !

ឆួង-ប៊ុត

បណ្ណាគារិកៈ

នៃបណ្ណាគារ ប៊ុត-ឆាង

ក្រុងភ្នំពេញ, នៅថ្ងៃទី ១ ខែសីហា ព.ស. ២៥០០ / គ.ស. ១៩៥៧

# គោលបំណងនៃការបង្រៀនអក្សរផ្ចង់

ការបង្រៀនសិស្សឲ្យសរសេរអក្សរផ្ចង់ គឺមានបំណងឲ្យសិស្សទម្លាប់ដៃ-ទម្លាប់ចិត្ត ឲ្យបាក់ផ្ចិតថ្នឹកតែខាងសរសេរឲ្យបានល្អត្រឹមត្រូវ មានរបៀបរៀបរយតាមបែបផែន ដែលអ្នកចេះដឹងបានរៀបចំចងជាក្បួនទុកមក ។ អ្នកណាចេះសរសេរអក្សរល្អ, អ្នកនោះនឹងទទួលផលប្រយោជន៍ជាទីគាប់ចិត្តពុំខាន ។

## ប្រយោជន៍នៃការចេះសរសេរអក្សរល្អ

១– សំបុត្រស្នាមដែលយើងត្រូវផ្ញើទៅគេ ដោយសរសេរអក្សរផ្ចិតផ្ចង់ នឹងនាំឲ្យអ្នកទទួលសប្បាយចិត្ត ចង់អានឥតធុញទ្រាន់ ហើយនាំឲ្យគេស្គាល់បានថា អ្នកផ្ញើមានច្បាប់ទម្លាប់តាមសុជីវធម៌ មិនមើលងាយគេ ។ បើសរសេរសំបុត្រឬកត់ត្រារឿងរ៉ាវអ្វី ដោយសរសេរអក្សរឲ្យតែរួចពីដៃទៅ នឹងនាំឲ្យគេអានពុំបាន បាត់ឬក៏ខុសសេចក្ដីដោយច្រឡំតួអក្សរ ឬដោយអានពុំបានសោះ មិនដឹងជាថាអ្វីយកជាការពុំកើតឡើយ ។

២– សំបុត្រឬបញ្ជីទាំងឡាយ ដែលសរសេរអក្សរច្បាស់លាស់ល្អ អាចនឹងទៅដល់ទីកន្លែងឬអាសយដ្ឋាននៃបដិគ្គាហកៈអ្នកទទួលដោយងាយៗ

៣– បើចេះសរសេរអក្សរល្អ នឹងល្បីឈ្មោះ ហើយមានជីវភាពសមរម្យប្រពៃ ដោយគេត្រូវការជួលឲ្យធ្វើការខាងកាន់បញ្ជី ឬគណនេយ្យជាដើម, ទោះក្នុងរាជការក្ដី ក្នុងជំនួញក្ដី បានទាំងអស់ ។

## សេចក្ដីពន្យល់ឬណែនាំក្នុងការបង្រៀនអក្សរផ្ចង់

របៀបបង្រៀនអក្សរផ្ចង់, សូមលោកគ្រូអ្នកគ្រូសម្រេចតាមយោបល់នៃកម្មវិធីរបស់លោកចុះ គឺបង្ហាត់ឲ្យសរសេរឈរ ឬទ្រេតបានឥតទាស់ៗ តាមទម្លាប់ច្រើនតែថ្នឹក ឬបាក់ដៃទៅតែខាងស្ដាំ, ទើបបង្រៀនឲ្យសរសេរផ្ដេកទៅស្ដាំ ឃើញថាងាយជាងរបៀបឯទៀត ។ ប៉ុន្តែបើទម្លាប់បង្រៀនឲ្យសិស្សសរសេរបែបណាមួយស្ទាត់ហើយ សូមកុំឲ្យសិស្សផ្លាស់ទៅសរសេរបែបណាមួយផ្សេងទៀតឡើយ ។ បំណែកអក្សរឈរល្អមើលជាងគេ តែពិបាកសរសេរជាងគេ គេពុំសូវចូលចិត្តសរសេរឡើយ ។

ក្នុងពេលដែលបង្រៀនសិស្សឲ្យរៀនសរសេរអក្សរផ្ចង់, លោកគ្រូត្រូវបង្រៀនតែមួយ ឬ ពីរតួបានហើយ ដើម្បីកុំឲ្យសិស្សហាត់សរសេររាត់តួព្យញ្ជនៈពុំរៀបរយ, លោកគ្រូត្រូវសរសេរពាក្យពេយ ឬ ពាក្យមួយឃ្លាឲ្យសិស្សសរសេរផង ៗ ធ្វើដូច្នេះ, ទើបសិស្សចេះសរសេររៀបរយ តួអក្សរមានទំហំ, មានចន្លោះ នឹងមានកំពស់ស្មើ ៗ គ្នា ។

នៅថ្នាក់កុមារដ្ឋាន-បរិវច្ឆណដ្ឋាន-អាធិកដ្ឋាន ការបង្រៀនសិស្សឲ្យសរសេរអក្សរផ្ចង់ តែពុនមធ្យមនឹងពុនតូចដែលធ្លាប់សរសេរធម្មតាតែ ២ ឬ ៣ បន្ទាត់បានហើយ ពីព្រោះម្រាមដៃសិស្សវានៅខ្ចីតាំងការសរសេរក៏នៅយឺតនៅឡើយនឹងឲ្យវាហាត់សរសេរពុនធំៗ ពុំទាន់បានទេ ។

ចាប់ពីថ្នាក់អាធិកដ្ឋានទៅទល់នឹងថ្នាក់ ឧត្ដមដ្ឋាន សឹមបង្រៀនអក្សរគំរូទាំងបីបែបដូចខាងក្រោមនេះ :

អក្សរផ្ចង់ធំ ៗ ពីរបន្ទាត់ (ECRITURE-GROSSE)

អក្សរផ្ចង់មធ្យម ឬ ពុនកណ្ដាល (ECRITURE MOYENNE)

អក្សរផ្ចង់តូច ៗ ពីរ ឬ បីបន្ទាត់ (ECRITURE FINE CURSIVE)

គំរូអក្សរផ្ចង់ទាំងអស់គេចែកជា ៧ ក្រុម តាមភាពអក្សរដែលមានលំនាំតួស្រដៀង ៗ គ្នាគឺ :

ក្រុមទី ១– រ វ អ

ក្រុមទី ២– ក ភ គ ត ឥ ឲ

ក្រុមទី ៣– ឞ ប ម ឫ ឬ ហ ឃ យ

ក្រុមទី ៤– ល ស ណ ឈ

ក្រុមទី៥– ឆ ជ ដ ឌ ឋ ថ ឯ

ក្រុមទី៦– ឈ ឃ ព ឭ ញ ឮ ឮ ឍ ឱ

ក្រុមទី៧– ខ ឧ ឪ ឲ ឳ ន ទ ឡ

x

x x

## របៀបបង្រៀនអក្សរផ្ចង់ថ្នាក់ដំបូង

១– គ្រូដឹកបន្ទាត់ស្របទីងបន្ទាត់ធៀងនៅក្តារខៀនទុកសរសេរអក្សរផ្ចង់គំរូ ដើម្បីឲ្យសិស្សមើលទីងសរសេរតាម ។

២– បង្គាប់សិស្សឲ្យដឹកបន្ទាត់នៅសៀវភៅសរសេររៀងខ្លួន ដូចគ្នានឹងបន្ទាត់ដែលដឹកនៅក្តារខៀន ។

៣– គ្រូសរសេរអក្សរផ្ចង់គំរូនៅក្តារខៀន ដើម្បីឲ្យសិស្សមើលទីងសរសេរតាម ។

៤– គ្រូត្រូវពន្យល់ទីងណែនាំទូវកិច្ចផ្សេងៗក្នុងរៀននេះ ដែលសិស្សត្រូវធ្វើ ឲ្យសិស្សសរសេរអក្សរបានល្អត្រឹមត្រូវតាមរបៀប ។

៥– បង្គាប់ឲ្យសិស្សសរសេរអក្សរផ្ចង់ ដោយយកគំរូពីក្តារខៀន ។

៦– គ្រូត្រូវដើរសាចុះសាឡើងតាមចន្លោះតុ ត្រួតមើលសិស្សសរសេរហើយទីងសង្កេតកែបង្គុយតម្រង់ដៃ.ជើង ការដាក់សៀវភៅ, ការកាន់ដងប៉ាកកាដែលសិស្សណាដាក់, កាន់ខុសទំនង, ឲ្យបានត្រឹមត្រូវឡើង ។ បើមានសិស្សណាសរសេររួចហើយ ត្រូវកែក្អាម ហើយដាក់ពិន្ទុឲ្យទៅដើម្បីឲ្យបានជឿនការទៅមុខ ។

៧– សៀវភៅសល់ពីនេះ ដែលកែនៅពេលនោះពុំទាន់, គ្រូត្រូវកែនៅពេលក្រៅពីម៉ោងបង្រៀន បើប្រសិនជាធ្លៀតកែបាន ។

x

x x

## គ្រូមានកិច្ចបីយ៉ាងក្នុងការបង្រៀនអក្សរផ្ចង់

១– សរសេរអក្សរផ្ចង់គំរូនៅក្ដារខៀន ដើម្បីឲ្យសិស្សសរសេរតាម;

២– ពន្យល់ដល់សិស្សនូវកិច្ចដែលត្រូវធ្វើ ដើម្បីនឹងឲ្យគេសរសេរតាមឲ្យបានល្អ;

៣– ឲ្យសិស្សសរសេរអក្សរផ្ចង់គំរូក្នុងសៀវភៅ ។

## របៀបបង្រៀនអក្សរផ្ចង់នៅថ្នាក់តូចៗ (១)

១– គ្រូគឹកបន្ទាត់ឆៀងនៅក្ដារខៀនបញ្ឈរមុនម៉ោងបង្រៀន ទុកសម្រាប់ឲ្យសិស្សហាត់សរសេរអក្សរផ្ចង់ ។

២– គ្រូចាប់ពន្យល់ទំនងបង្គុយសរសេរ, ការដាក់ដៃ-ជើង, ការដាក់សៀវភៅ នឹងការកាន់ដងប៉ាកកាតាមបែបបទ ឲ្យសិស្សធ្វើតាម ។

៣– គ្រូត្រូវឈរមុខក្ដារខៀន បែរខ្នងទៅរកសិស្ស ហើយសរសេរមួយៗ នូវអក្សរផ្ចង់លើអាកាសទទេ ដោយគូសតួអក្សរនឹងចង្អុលដៃតាមខ្សល់អក្សរឲ្យសិស្សមើល «កិច្ចនេះត្រូវធ្វើមួយដង ឬ ពីរដង ឲ្យសិស្សចំណាំជាដំបូង» ។

៤– គ្រូត្រូវបង្គាប់សិស្សទាំងអស់ឲ្យកាន់ដីស, ដៃខ្មៅ ឬដងប៉ាកកា រួចគ្រូនឹងសិស្សប្រាប់សរសេរអក្សរផ្ចង់ ដោយគូសនឹងចង្អុលដៃព្រដឹកាកាស ពីរបីដងម្នាក់ ។

៥– រួចគ្រូបែរមុខមករកសិស្សវិញ ហើយបង្គាប់សិស្សខ្លះឲ្យសរសេរព្រដឹកាកាសទៀត រួចទើបបង្គាប់សិស្សឲ្យសរសេរគូសដោយចង្អុលដៃលើអាកាសទៀត ។

៦– គ្រូហៅសិស្សពីរបីនាក់ ឲ្យទៅសរសេរអក្សរផ្ចង់ ដែលសរសេរគូសដោយចង្អុលដៃលើអាកាសអម្បាញ់មិញ នៅលើក្ដារខៀនទៀត ។

---

១ ការបង្រៀនអក្សរផ្ចង់នៅថ្នាក់តូចៗ សព្វថ្ងៃនេះ, គេមិនចាប់ឲ្យសិស្សគឹកបន្ទាត់ស្របទ្រេតគ្នាទេ, គេឲ្យសរសេរតែ ១ កាត ទំហំ២០ត្នាត់ស្របត្រង់តាមបន្ទាត់ដែលគេមានគឹកស្រាប់ក្នុងសៀវភៅក៏បានហើយ ។

៧- គ្រូបង្គាប់ឲ្យសិស្សក្នុងថ្នាក់ ចាប់សរសេរតួអក្សរផ្ចង់នៅក្ដារខៀន (កិច្ចនេះ, ជាការពិសោធន៍មើល តើសិស្សក្នុងថ្នាក់ទាំងអស់អាចសរសេរបានត្រូវគ្រប់គ្នាឬទេ; បើមានសល់ខុះ, ត្រូវពន្យល់ឲ្យវាសរសេរឲ្យត្រូវដូចគ្នាទាំងអស់ឡើង) ។

៨- គ្រូចាប់សរសេរអក្សរគំរូនៅក្ដារខៀនតាមបន្ទាត់ដែលបានដឹកហើយ ដើម្បីឲ្យសិស្សបំណាំសរសេរតាម ។

៩- គ្រូបង្គាប់សិស្សទាំងអស់ឲ្យសរសេរអក្សរផ្ចង់ក្នុងសៀវភៅរៀនខ្លួន តាមអក្សរផ្ចង់គំរូលើក្ដារខៀន ។

១០- គ្រូត្រូវឧស្សាហ៍ដើរសាចុះសាឡើងតាមចន្លោះតុ ដើម្បីកែបង្គុយសិស្ស, កែរបៀបដាក់សៀវភៅសរសេរ, កែរបៀបកាន់ដងប៉ាកកា ។ ពេលដែលដើរត្រួតនេះ, បើសិស្សណាសរសេររួចហើយ គ្រូត្រូវកែរបស់សិស្សនោះឲ្យហើយ ព្រមទាំងឲ្យពិន្ទុវាឲ្យរួចតែម្ដងទៅដើម្បីឲ្យបានជឿនការទៅមុខ ។

១១- សៀវភៅដែលសល់ពីនេះ, ត្រូវយកទៅកែឯផ្ទះ ឬកែនៅពេលមុនម៉ោងបង្រៀនឲ្យហើយស្រេចតែម្ដងទៅក៏បាន ។

x

x x

## លក្ខណសម្បត្តិដែលត្រូវប្រព្រឹត្តក្នុងការសរសេរអក្សរផ្ចង់

### សម្រាប់អក្សរជ្រៀង

ក- បង្គុយៈ ១- ត្រូវអង្គុយឲ្យឃ្លាតដងខ្លួនពីហាមតុ, ឲ្យត្រង់ខ្លួនទីងឲ្យស្របទៅតាមតុ កុំឲ្យទ្រេតទៅឆ្វេង ឬទៅស្ដាំ (ហាមផ្ដាច់កុំឲ្យប៉ះដើមទ្រូងទៅទីងហាមតុ) ។

២- ក្បាលត្រូវឱនមកមុខបន្តិច ។

៣- ជើងស្ដាំត្រូវសណ្ដូកត្រង់ទៅក្រោមឲ្យដល់ដី ។ ជើងឆ្វេងត្រូវសណ្ដូកបញ្ចិតឲ្យលៀនទៅមុខជាងជើងស្ដាំបន្តិច ។

៤- បាតជើង ឬ ប្រអប់ជើងត្រូវដាក់ឲ្យរាបទីងដី ហើយបំបែរចុងជើងចេញក្រៅបន្តិច ។

៥- ដៃឆ្វេងដែលទ្រទម្ងន់ខ្លួនយ៉ាងស្រាលបន្តិច ត្រូវបត់ឲ្យស្របតាមកែមតុ ។

៦–.ចុងដៃឆ្វេង ត្រូវទប់នឹងសង្កត់សៀវភៅដូចម្ដេចតាមបំណង ។

៧– ដើមដៃស្ដាំប្រត់យ៉ាងស្រាលលើតុក្បែរហាមសៀវភៅ ។ នេះ ត្រូវដាក់បែរធៀងទៅឆ្វេងបន្តិច ។ ដើមដៃស្ដាំនេះ ត្រូវដកឲ្យឃ្លាតពីដងខ្លួនចំនួន ៤ ធ្នាប់ ។

ខ– ការកាន់ដងប៉ាកកា: ១– ត្រូវកាន់ដងប៉ាកកាតម្រង់ចុងឆ្ពោះទៅស្មាស្ដាំ នឹងកាន់ទប់ដោយម្រាមដៃបី (មេដៃ, ចង្អុលដៃ នឹងម្រាមវែង គឺម្រាមកណ្ដាល ឬចង្អុលខ្មោច) ឲ្យមានទំនងគោង ឬ ខុបចូលបន្តិច ដើម្បីនឹងរុញទាញស្លាបប៉ាកកាឲ្យជិតស្រួល ។

២– ចុងដៃសង្កត់ផ្ទប់យ៉ាងស្រាលលើកូនដៃនឹងនាងដៃដែលត្រូវបត់ចូលបន្តិច ។

៣– ក្រចកនៃម្រាមកណ្ដាលទល់ចុងខាងក្រោមនៃដងប៉ាកកា ។

៤– ស្លាបប៉ាកកាត្រូវឲ្យប៉ះចុងទាំងពីរដល់ក្រដាសជាដរាប ។ ការសង្កត់ស្លាបប៉ាកកាធ្ងន់នឹងបន្ទើរ បណ្ដាលឲ្យដិតធំនឹងស្ដួចតូចចំណែកផ្សេងៗនៃតួអក្សរ ។ អក្សរខ្មែរគេច្រើនសរសេរនៅក្រោមបន្ទាត់ ។

គ– ដំបូន្មានអំពីការសរសេរ: ១– ក្មេងត្រូវសំឡឹងចម្ងាយ ៣០ សង់ទីម៉ែត្រទៅក្រដាសដែលប្រុងនឹងរាសតួអក្សរតទៅ ។ កុំមើលតួអក្សរដែលសរសេររួចមកហើយ ។

២– កាលណាសរសេរផុតតួមួយហើយ, ត្រូវប្រយ័ត្នក្នុងការចាប់សរសេរតួមួយទៀត ក្រែងមិនស្របគ្នានឹងតួមុន គឺត្រូវឲ្យស្របគ្នាជាដរាប ទើបត្រូវ ហើយល្អមើលផង ។

៣– បើចង់ឲ្យសរសេរអក្សរតាប់ល្អ, ត្រូវទម្លាប់សរសេរទាញពីលើចុះក្រោម, កុំទាញពីក្រោមឡើងទៅលើឡើយ ។ ចំណែកអក្សរប៉ាក់វិញ, បើទាញពីលើចុះក្រោមគោងសង្កត់, បើទាញពីក្រោមទៅលើគោងបន្ទើរស្លាបប៉ាកកា ។

៤– ហាត់ផ្គុំតួអក្សរជាកំណាត់ៗ ឬ មួយតួៗ សឹមទាញបញ្ចប់ ឬ គួបជាក្រោយ ដើម្បីឲ្យតួអក្សរចុះស្របគ្នា ។

៥– របៀបសរសេរអក្សរឈរក៏មានទំនងប្រហែល ៗ គ្នា ប៉ុន្តែត្រូវប្រើស្លាបប៉ាកកាចុងរើបន្តិចជាងសរសេរអក្សរជ្រៀង ។

៦– សៀវភៅត្រូវដាក់ឲ្យចំពីមុខដើមទ្រូង ឲ្យស្របទៅតាមគែមតុ កុំបញ្ឆៀងឡើយ ។

៧– របៀបសរសេរអក្សរខមុ ឬ មូល ក៏មានបែបបទប្រហែល ៗ គ្នា ប៉ុន្តែដៃស្តាំត្រូវផ្ងារបែរបន្តិចទៅខាងស្តាំ ហើយម្រាមដៃត្រូវប្រមូលផ្តុំគ្នាបន្តិច ។ ឯសៀវភៅក៏ត្រូវដាក់ចំពីមុខឲ្យត្រង់ស្របតាមបណ្តោយតុដែរ ។ ដងប៉ាកកាត្រូវកាន់បញ្ឈរបោត ។

៨– រៀនត្រលៀសចុងម្រាមកណ្តាល ដើម្បីឲ្យចុងស្លាបប៉ាកកាផ្គុំតួអក្សរឲ្យបានរង្វង់ទ្រង់ទ្រាយតាមបំណង ។

៩– ឯអក្សរទំនើប (ម៉ូត) គ្រប់បែប, គេច្រើនប្រើដឹកបន្ទាត់ (តួអក្សរ) ឲ្យតួអក្សរបានត្រឹមត្រង់សរសៃល្អ ។

x
x x

## សេចក្តីណែនាំ

១– ការដឹកបន្ទាត់សរសេរអក្សរផ្ចង់, មុនដំបូងគេត្រូវដឹកបន្ទាត់ស្របសិន, រួចទើបបានគេដឹកបន្ទាត់ទ្រេតជាខាងក្រោយ, បើប្រសិនជាសៀវភៅមានបន្ទាត់ស្របត្រង់ស្រាប់ហើយ, នោះត្រូវលៃតាមខ្នាត ដឹកបន្ថែមតែបន្ទាត់ទ្រេតតែម្តងទៅទុកជាការស្រេច ។

២– របៀបដឹកបន្ទាត់ទ្រេតនោះ, ត្រូវគូសផ្ទៃ ៤ ជ្រុងស្មើនៅដើមបន្ទាត់, ក្នុងផ្ទៃ ៤ ជ្រុងនេះ គេត្រូវបែងជាបួនជ្រុងស្មើកាតគ្នា, រួចត្រូវដឹកបន្ទាត់ទ្រេតពីលើ ដើម្បីយកជាគំរូសរសេរតួអក្សរឲ្យទ្រេតទៅតាមបន្ទាត់ដែលដឹកនោះ, កុំឲ្យតួអក្សរវៀចចុះវៀចឡើង តាមអំពើចិត្តអ្នកសរសេរ ។

៣– ដឹកបន្ទាត់ទ្រេតពីលើ ត្រូវដឹកលៃឲ្យចំជ្រុងមុមបន្ទាត់ខាងស្តាំ; ឯចុងបន្ទាត់ខាងក្រោម ត្រូវដឹកទម្រេតឲ្យចំជ្រុងមុមបន្ទាត់កណ្តាល, បើអក្សរខ្នាតតូច ត្រូវលៃយកតាមខ្នាតតួអក្សរធំចុះ (គំរូដឹកបន្ទាត់មាននៅក្នុងក្រុមអក្សរផ្ចង់ទី ១ ខាងមុខស្រាប់) ។

៤– បន្ទាត់ដឹកសរសេរអក្សរផ្ចង់ គេត្រូវដឹកជា ៤ ឬជា ៦ ហើយបន្ទាត់ដែលលើសពីសរសេរតួអក្សរនោះ, គេត្រូវយកបន្ទាត់នោះធ្វើជាខ្នាតវាត់ជើងវាត់សក់ឡើង-ចុះ ដើម្បីឲ្យទៀងទាត់ ។

x
x x

# គំរូបង្គុយក្នុងការសរសេរ




បង្គុយល្អ          បង្គុយមិនល្អ

ចូរអ្នកទម្លាប់ នូវអាកប្បកិរិយារបស់អ្នក ឲ្យល្អក្នុងការសរសេរ ដើម្បីធ្វើឲ្យអដ្ឋិសន្ធិលិកៈរបស់អ្នករៀបរយល្អ ។

កាលណាអ្នកសរសេរ ចូរអ្នកអង្គុយឲ្យត្រង់ដងខ្លួន ដូចជាកូនសិស្ស ក និង ខ ព្រោះអ្នកអង្គុយដូច្នេះ នាំឲ្យអ្នកដកដង្ហើមបានស្រួល ត្រូវតាមក្បួនវិទ្យាសាស្ត្រនិងអនាម័យ ។

ប៉ុន្តែ, បើអ្នកអង្គុយមិនល្អ ដូចជាកូនសិស្ស គ និង ឃ នោះអ្នកនឹងរៀចឆ្អឹងខ្នង ហើយធ្វើឲ្យរាងកាយរបស់អ្នកមានសុខភាពពុំបរិបូណ៌ផង ។



# កំរូបន្ទាត់ដឹកសរសេរអក្សរផ្ចង់

## ( អក្សរជ្រៀង )

ខ្ញុំកាន់ស្លាបប៉ាកកាខ្ញុំដោយម្រាមដៃបី បង្រួមចូលគ្នាបន្តិច, ខ្ញុំសង្កត់ដៃខ្ញុំលើម្រាមពីរក្រោមនេះ ។ បើដៃខ្ញុំដាក់សិប់ហើយគេមើលបាតដៃខ្ញុំពុំឃើញឡើយ, ហើយផងប៉ាកកាខ្ញុំបែរចុងត្រង់ទៅរកស្មាខ្ញុំ ។

## ក្រុមទី ១

១ ២

ររអ អារ រអារ រអើររអួរ

សេចក្តីសំគាល់: ដើម្បីកុំឲ្យទទើសទទែងចង្អៀតចន្លោះបន្ទាត់ ហើយឲ្យសមផង, តួអក្សរត្រូវសរសេរមួយភាគ; ស្រៈ ទឹង សក់ វាត់ទៅលើយកកន្លះភាគ, ស្រៈចុះក្រោមដូចជា: « ុ ូ » យកបីភាគបួន (៣/៤) ។

ឯតួអក្សរមធ្យម ទឹងតួ ត្បូងប្បង្ហារ ត្រូវលៃតួ, សក់, ជើង ឬស្រៈ តាមលំនាំតួអក្សរធំខាងលើ ។

# ក្រុមទី ២

## អក្សរជ្រៀង ធំ, មធ្យម, កណ្ដាល

ក ភ គ ត ឥ ឡៅកត់ ភក្ត គភិ

ក ភ គ ត ឡៅ ឥតីបិ ពុកកើពុក ភិតពុក ឥគី ឥត់គុ

ក ភ គត ឥ ឡៅ កោះ គោ គត់តក់ ភូត ភកី ភក់

សេចក្ដីសំគាល់: តួអក្សរ ១ភាគ, សក់ខ្សញា ពីខាងលើកន្លះភាគ (១/២) ។ ស្រះខ្ជើងក្រោមបីភាគបួន (៣/៤) ។ ឯតួមធ្យមនឹងតួតូចខ្នារ ត្រូវយកតាមរបៀបតួធំខាងលើ ។

# ក្រុមទី ៣

## អក្សរជ្រៀង ធំ, មធ្យម, កណ្ដាល

ច ប ម ឬ ឫ ហ ឃ យ ចាបយំឃាយ

ច ប ម ឬ ឫ ហ ឃ យ ចាម ចាប់ចាប ឬ ចាប់យាយមាច

ច ប ម ឬ ឫ ហ ឃ យ យាយយូ ចាប់បាយបាច យាយមាចចាមាត់ហូបបាយ

សេចក្ដីសំគាល់ : ចុងខ្នងតួអក្សរ ឬ ត្រូវដាក់ចំបីភាគបួន (៣/៤) នៃតួអក្សរ ៗ តួ ម ក៏ត្រូវវះពោះបំពាក់កណ្ដាលភាគនៃតួអក្សរ ៗ ជើង ឬ ឫ ត្រូវទាញមកមុខឲ្យស្មើនឹងតួលើ ហើយរង្វង់កោងក្រោមបង្អស់ ក៏ត្រូវឲ្យចុះក្រោមទល់នឹងកណ្ដាលភាគនៃតួដែរ ៗ

# ក្រុមទី ៤

## អក្សរទ្រៀង ធំ, មធ្យម, កណ្ដាល

ល ស ណ ឈ លោះណា សំណាសល់

លសណឈ ឈើលៃ លឹណ លោណ សំណល់ សំណុំ

ល ស ណឈ ស៊ីល្បែស ឈើលាស់

សេចក្ដីសំគាល់ ៖ អក្សរ ល, ស, ណ, ឈ ត្រូវសរសេរទាញខ្សែគំនូសមុខក្រោយនឹងកណ្ដាល ឲ្យមានទំហំនឹងចន្លោះប៉ុនៗគ្នា ។ ឯក្បាល ស ត្រូវសរសេរឲ្យទាបជាងកន្ទុយបន្តិច ដល់បន្ថែមសក់មក ឲ្យមានកំពស់ស្មើគ្នានឹងកន្ទុយក្រោយ ។

# ក្រុមទី ៥

## អក្សរជ្រៀង ធំ, មធ្យម, កណ្ដាល

ដជឌផបឋឯ ជឹងផង ឯងថ្លឹង

ដឹ ដឺ ជឺ ផឹ បី ឋឹង ឯងថា ឋិផា ដាំផ្លួង ជីជុំ ផឺផ្គង់ ដាផបាំង

ដ ជ ឌ ផ ប ឋ ឯ ដែឯង ជងថ្លឹង ឌូងដុះ

សេចក្ដីសំគាល់: តួ ដ ជ ឌ ចាប់ផ្ដើមសរសេរពីក្រោមបន្ទាត់ចំនួនបីភាគបួន(៣/៤) ហើយវាត់ចុងនឹងសក់ទៅលើកន្លះភាគ, កន្ទុយ ជ ឌ គ្មានខ្វែចចុងទេ ។ ឯចុងខ្វែចតួ ផ ប ក៏ត្រូវទាញបីភាគបួន(៣/៤)នៃតួអក្សរ ។ ក្បាល ឋ ត្រូវទាញខ្វែចក្បាលឲ្យដល់បន្ទាត់លើ, ឯកន្ទុយក្រោយត្រូវវាត់ទៅលើកន្លះភាគ(១/២) នៃតួអក្សរ ។ ក្បាល ឯ ត្រូវស្ទួនឲ្យនៅត្រង់បីភាគបួន(៣/៤)នៃតួអក្សរ ។ ឯចុងកន្ទុយត្រូវវាត់ទៅលើកន្លះភាគ(១/២) នៃតួអក្សរ ។

# ក្រុមទី ៦

## អក្សរជ្រៀង ធំ, មធ្យម, កណ្ដាល

ឆ ឈ ព ឮ ញ ព ឭ ឈ ឱ ឆាឆៅ ឈុំឆា

ឆ ឈ ព ឮ ញ ព ឭ ឈ ឱ ព្រឆា ពេញពោះ ឈឺពោះ

ឆ ឈ ព ឮ ញ ព ឭ ឈ ឱ ឆាឆី ឈុញ ឈ្មោញ ញ៉ាំឆៅ ពរពញើឈឺពេញពោះ

សេចក្ដីសំគាល់ៈ ចុងខ្បត់ឆ្ន ទីង ឬ ត្រូវសរសេរទាញឡើងឲ្យទល់បីភាគបួន(៣/៤) ។ ជើង ឮ ជើង ឭ ទីង ឭ ត្រូវទាញវាត់ឲ្យត្រឹមតួ, ឯរន្ធន់កោងក្រោមបន្តស់ ត្រូវទាញចុះក្រោមទល់ពាក់កណ្ដាលភាគនៃតួ ។ រន្ធន់ក្បាល ឡ ត្រូវទាញចុះទល់ទីងបីភាគបួន (៣/៤); ឯចុង ជើង ឡ ត្រូវទាញចុះក្រោមមួយភាគបួន (១/៤) ។

ជនបា៉កកា

ដាក់ស្វាបធម្មតា



# ក្រុមទី ៧

## អក្សរជ្រៀង ធំ, មធ្យម, កណ្ដាល

ខ ឧ ឪ ឩ ឪ ន ទ ឡូ ោ ឿ

ខ ឧ ឪ ឩ ឪ ន ទ ឡូ ឡាន ខាំនំ ឡូឡា ខំនាំទៅ

ខ ឧ ឪ ឩ ឪ ន ឡូ ខានទៅ ខខ ឪខិន ឪឡូ ខែនេះ

១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១២៣៤៥៦៧៨៩១០

សេចក្ដីសំគាល់: ក្បាល ខ ចាប់គូសរង្វង់ពីក្រោមទៅលើភាគពីរ រួចទាញកន្ទុយចុះក្រោមភាគបី ហើយទាញឡើងទៅលើវិញឲ្យស្មើនឹងខ្នងក្បាល ។ ឧ ឪ ឩ ឪ សរសេរដូចគ្នានឹងតួ ខ ប៉ុន្តែទាញជើងពីតួចុះក្រោមមួយភាគបួន (១/៤) ។ តួ ន ចាប់ទាញពីលើចុះក្រោមពីរភាគ កាច់រង្វង់ពោះឡើងទៅលើវិញ ឲ្យទល់នឹងចុងដែលចាប់ទាញមក ហើយពត់រង្វង់មូលទៅភ្ជាប់នឹងចុងខ្នង ។ តួ ទ ធ្វើប្រហែលគ្នានឹងតួ ន ដែរ ។ ឯតួ ឡូ ដូចគ្នានឹងតួ ទ ប៉ុន្តែទាញជើងចុះក្រោមពាក់កណ្ដាលភាគនៃតួ ។ លេខសរសេរបានពីរយ៉ាង: បើកាលណាសរសេរឲ្យមានចុងតួវែង ត្រូវកាត់ចុងទៅលើកន្លះភាគ (១/២), កាត់ចុងចុះក្រោមកន្លះភាគពីតួលេខ ។ បើសរសេរឲ្យខ្លីស្មើនឹងតួក៏បាន ។

# ស្រះពេញតួ

អក្សរជ្រៀង សរសៃស្មើ

អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ អុំ អំ

អាំ អះ

ស្រះពេញតួ នេះ មានពន្យល់អំពីរបៀបសរសេរនៅក្រុមអក្សរផ្ចង់ខាងដើម ។

# អក្សរជ្រៀង

## សរសៃធំស្មើ

ក ខ គ ឃ ង  ច ឆ ជ ឈ ញ

្ក ្ខ ្គ ្ឃ ្ង  ្ច ្ឆ ្ជ ្ឈ ្ញ

ដ ឋ ឌ ឍ ណ  ត ថ ទ ធ ន

្ដ ្ឋ ្ឌ ្ឍ ្ណ  ្ត ្ថ ្ទ ្ធ ្ន

ប ផ ព ភ ម  យ រ ល វ ស

្ប ្ផ ្ព ្ភ ្ម  ្យ ្រ ្ល ្វ ្ស

ហ ឡ អ ។

្ហ ្ឡ ្អ

គំរូអក្សរជ្រៀងនេះ មានសរសៃស្មើគ្នាដូចជាសរសេរនឹងដីសដែរ ។

ជើង «្ព» ប្រើបានពីរយ៉ាងគឺ: «ព, ្ព» ឧទាហរណ៍: «បោះពុម្ព, គុម្ពឈើ, សព្វថ្ងៃ, សព្វាវុធ» ជាដើម ។

# អក្សរឈរ

## សរសៃធំស្មើ



ក ខ គ ឃ ង ច ឆ ជ ឈ ញ

្ក ្ខ ្គ ្ឃ ្ង ្ច ្ឆ ្ជ ្ឈ ្ញ

ដ ឋ ឌ ឍ ណ ត ថ ទ ធ ន

្ដ ្ឋ ្ឌ ្ឍ ្ណ ្ត ្ថ ្ទ ្ធ ្ន

ប ផ ព ភ ម យ រ ល វ ស

្ប ្ផ ្ព ្ភ ្ម ្យ ្រ ្ល ្វ ្ស

ហ ឡ អ ។

្ហ ្ឡ ្អ

អក្សរ ឈរ នេះ មានសរសៃធំស្មើដូចជាសរសេរនឹងដីសដែរ ។

ពាក្យណែនាំ

ខ្ញុំកាន់ដងប៉ាកកា បញ្ឈរបន្តិច ហើយ នឹងផ្ងារដៃទៅស្តាំ បន្តិច; ខ្ញុំក្តាបផ្គុំ ម្រាមដៃខ្ញុំបន្តិចៗ



# អក្សរខម

## របៀបប្រើស្លាបប៉ាកកា

អក្សរមូលបារាំងគេសរសេរនឹងស្លាបប៉ាកការ៉ុង, ចំណែកខាងអក្សរ ខម ឬ មូល ខ្មែរសរសេរបានគ្រប់ស្លាបប៉ាកកា។ បើចង់ឲ្យជិតខ្លាំងមានសរសៃធំនឹងឆ្មារ, នោះត្រូវប្រើស្លាបប៉ាកការ៉ុងដូចបារាំងដែរ ។

## អក្សរខមកកជើង



ក ខ គ ឃ ង ច ឆ ជ ឈ ញ

ដ ឋ ឌ ឍ ណ ត ថ ទ ធ ន

ប ផ ព ភ ម យ រ ល វ ស

ហ ឡ អ ។

អក្សរ ខម ឬ មូល ច្រើនមានប្រើក្នុងក្បួនខ្នាត សាស្ត្រាស្លឹករឹតសម័យបុរាណ ។ សម័យបច្ចុប្បន្ននេះគេច្រើនប្រើដាក់ចំណងជើងសៀវភៅ, យីហោ, បដា ។ល។ ព្រោះមានតួនឹងសរសៃធំ គួរជាទីទស្សនា ។

# អក្សរខមមានជើង

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម យ្យ រ្រ ល្ល វ្វ ស្ស

ហ្ហ ឡ្ឡ អ្អ ។



# អក្សរមូលមានជើង

## សម័យបុរាណ(១)

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម យ្យ រ្រ ល្ល វ្វ ស្ស

ហ្ហ ឡ្ឡ អ្អ ។

១ មានប្លែកពីអក្សរ ១៨ សម័យបច្ចុប្បន្ន ៥ តួ គឺៈ ក គ ង ដ វ

# អក្សរមូល

## ឥតជើង

ក ខ គ ឃ ង ច ឆ ជ ឈ ញ

ដ ឋ ឌ ឍ ណ ត ថ ទ ធ ន

ប ផ ព ភ ម យ រ ល វ ស

ហ ឡ អ ។

# អក្សរខម

## មានស្រមោល

ក ខ គ ឃ ង ច ឆ ជ ឈ ញ

ដ ឋ ឌ ឍ ណ ត ថ ទ ធ ន

ប ផ ព ភ ម យ រ ល វ ស

ហ ឡ អ ។

អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ

ឱ ឳ អុំ អំ អាំ អះ

# អក្សរ ខម - ឈរ

រចនាដោយលោកម៉ែន-អ៊ាញ



## ឃាបអក្សរខ្មែរ
## បែបហាត់ខេនសើកដម្បង



## នមោពុទ្ធាយសិទ្ធំ

កខគឃង ចឆជឈញ ដឋឌឍណ តថទធន

បផពភម យរលវសហឡអ

កខគឃង ចឆជឈញ ដឋឌឍណ តថទធន បផពភម យរលវសហឡអ

អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ អុំ អំ អាំ អះ

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ

ក កា កិ កី កឹ កឺ កុ កូ កួ កើ កឿ កៀ កេ កែ កៃ កោ កៅ កុំ កំ កាំ កះ

១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០-១០០-១.០០០-១០.០០០

# គំរូអក្សរក្បាច់

រចនាដោយ លោក ម៉ែន-អ៊ាញ និង លោក នូ-រៀន








# គំរូអក្សរក្បាច់

រចនាដោយលោក ម៉ែន-អ៊ាញ និង លោក ទូ-វៀន



គំរូដឹកបន្ទាត់




# អក្សរផ្ចង់បារាំង



ក្រុមទី ១

អក្សរជ្រៀង (តូច)

ALPHABET MAJUSCULE




អក្សរផ្ចង់បារាំង យើងបានរើសយកតែ ៤ ក្រុមមកធ្វើជាគំរូគឺ: ជ្រៀង (តូច), ជ្រៀង (ធំ), ឈរ, ក្បាច់ សម្រាប់សិស្សថ្នាក់តូច ៗ ហាត់សរសេរ; ព្រោះប្រទេសយើងនៅមានប្រើអក្សរបារាំងខ្លះនៅឡើយ ។

## ក្រុមទី ២

### អក្សរជ្រៀង (ធំ)



## ក្រុមទី ៣

### អក្សរឈរ (តូច)

### ALPHABET MAJUSCULE DE LA RONDE





ក្រុមទី ៤

អក្សរក្បាច់




អក្សរពុម្ព (ធំ)

ABCDEFGHIJKLMNOPQRSTUVWXYZ

អក្សរពុម្ព (តូច)

abcdefghijklmnopqrstuvwxyz

100891
PBC STATIONERY
$ 0.65